

# ឡាំងប៉េងសៀក

(១៩៤៦-១៩៧៥?)

កើតនៅថ្ងៃ ២០ខែកក្កដា ១៩៤៦ នៅខេត្រកំពង់ធំជាកូនលោកឡាំងបេ មេឃុំ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្រកំពង់ធំ។[1]

រៀននៅបឋមសិក្សា និង មធ្យមសិក្សាបឋមភូមិ នៅ កំពង់ធំ។ ក្រោយមក ចេញមកបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ

[1] ជីវប្រវត្តិលោកឡាំងប៉េងសៀក ទាញចេញពីក្របសៀវភៅប្រលោមលោក ដោយបន្ថែមពត៌មានខ្លះៗទៀត។សូមអានបន្ថែម «ឡាំងប៉េងសៀក» ក្នុងសៀវភៅ ឃីងហុកឌី, *អក្សរសិល្ប៍សតវត្សទី២០ ករនិពន្ធនិងកម្រងអត្ថបទ*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧, ទំព័រ ៣២៩ដល់៣៣៤។

*នាវិទ្យាល័យស៊ីសុវត្ថិ។ រៀនពូកែខាងមុខវិជ្ជាតែងសេចក្តីខ្មែរ តែមុខវិជ្ជានានាឯទៀតមិនជាពូកែទេ។ ឡាំងប៉េងសៀកផ្តើម ការតែងនិពន្ធតាំងតែនៅរៀនក្នុងមធ្យមសិក្សានៅឡើយនាឆ្នាំ១៩៦៣។*

*បន្ទាប់ក្រោយមកនាឆ្នាំ១៩៦៤ យុវជនឡាំងប៉េងសៀក ចូលរៀននៅមហាវិទ្យាល័យច្បាប់ អស់រយៈ ពេល ២ឆ្នាំរហូតដល់បានទទួល «សញ្ញាប័ត្រ សមត្ថភាពច្បាប់»* (Diplôme de Capacité en Droit) *ព្រោះលោកគ្មានសញ្ញាប័ត្រមធ្យមសិក្សាទី២* (Bacc II) *អាចចូលរៀនយក បរិញ្ញាប័ត្រច្បាប់* (Licence en Droit) *បាន។ លោកបានប្រឡងចូលធ្វើការក្នុងក្រសួងយុត្តិធម៌ ក្នុងក្របខណ្ឌ រដ្ឋការជាសមុហបញ្ជី* (commis greffier du tribunal) *នៅក្រសួងយុត្តិធម៌ នាឆ្នាំ១៩៦៧។*

*នាឆ្នាំ១៩៦៨ ប្រហែលជាក្រសួងបញ្ជូនលោកឲ្យទៅ «បម្រើការក្នុងយោធា»*[2] (Service militaire obligatoire) *រយៈពេលមួយឆ្នាំ។ នេះជា កាតព្វកិច្ចចាំបាច់ចំពោះ មន្ត្រីរដ្ឋការជាបុរសជាពិសេសនៅ*

---

[2] *ឡាំងប៉េងសៀកបានសរសេរនៅកថាមុខ ថា៖«ថ្វីបើរឿង «**ខ្យល់កាំបុតត្បូង**» នេះ សរសេរចប់តាំងពីឆ្នាំ១៩៦៨មកហើយក៏ដោយ, រឿងនេះពុំបានចូលរួមក្នុងការប្រឡងអក្សរសាស្ត្រដែលសមាគមអ្នកនិពន្ធខ្មែរចាត់ចែងនោះឡើយ, ព្រោះរយៈពេលនោះ **<u>ខ្ញុំជាអ្នកនិពន្ធជាប់បំពេញកម្មសិក្សាផ្នែកយោធាវិជ្ជា</u>** … រកពេលកែសម្រួលឲ្យត្រូវតាមកាលៈទេសៈស្រុកទេសមិនបាន។»(សរសេរចប់នៅរ៉ឺនសែ នៅថ្ងៃទី ៣០ខែតុលា១៩៦៨ កែសម្រួលចប់ នៅភ្នំពេញថ្ងៃទី១មេសា១៩៧២)។ «កថាមុខ» ក្នុងរឿង «**ខ្យល់កាំបុត ត្បូង**», ភ្នំពេញផ្សាយចេញពី សមាគមអ្នកនិពន្ធខ្មែរ, ១៩៧២, ទំព័រ គ។*

*លីវ*[3] *ទើបចូលធ្វើការបម្រើរដ្ឋការ នៅសម័យសង្គមរាស្ត្រនិយម ហើយបានធ្វើបេសកកម្ម ដំបូងនៅ វ៉ឺនសៃនាខេត្ត រតនគីរី*[4]*។ ពេល បំពេញចប់ កាតព្វកិច្ចបម្រើយោធា១ឆ្នាំមកហើយ លោកត្រឡប់ មកកាន់តំណែងដើមវិញនៅក្រសួងយុត្តិធម៌។នាសម័យសាធារណ រដ្ឋខ្មែរ លោកប្រហែលជាត្រឡប់ចូល ធ្វើទាហានវិញរវាងឆ្នាំ ១៩៧១ព្រោះលោកជានាយទាហានបម្រុងរដ្ឋការ* (Officier de réserve)។

---

[3] *ចាប់ពីសម័យសង្គមមក រវាងឆ្នាំ១៩៥៥ ដល់ ១៩៧០ មានច្បាប់ចែង ពី ‹កាតព្វកិច្ចបម្រើក្នុងយោធា› ឬ ‹ហៅក្រោមទង់ជាតិ›* (Service militaire obligatoire ou Appeler sous le drapeau) *នេះ ជាការជ្រើសរើស មន្ត្រីរដ្ឋដែល នៅលីវឱ្យចូលបម្រើយោធាក្នុងរយៈពេលមួយឆ្នាំ គឺ៦ខែហ្វឹកហ្វឺកយោធាវិជ្ជានិង ៦ខែទៀតបម្រើក្នុងកងទ័ព។*

[4] *សូមអាន សេចក្តី «**ជម្រាបអ្នកអាន**» ក្នុងប្រលោមលោក ឡាំងប៉េងសៀក «**ស្រដេះ ស្រដោច**» នៅទំព័រ ១៧៨៖ «**ស្រដេះស្រដោច**» ចែងពី ជីវិតពិតៗ របស់មិត្តកំសត់មួយរូប «មាស-ម៉ានិល» ដែលក្នុងពេលឥឡូវមិត្តបានប្រគល់ សង្ខារទៅ អទិទេពវិញហើយ។*

*រឿងនេះខ្ញុំបានសរសេរដំបូងនៅឆ្នាំ១៩៦៣ កាលខ្ញុំនៅជាសិស្សថ្នាក់ទី២ នៃវិទ្យាល័យព្រះស៊ីសុវត្ថិ «បច្ចុប្បន្នវិទ្យាល័យភ្នំដូនពេញ»។ ដូច្នេះគួររាប់ «ស្រដេះ ស្រដោច»នេះ ជា«បុត្រច្បង»ក្នុងកិច្ចនិពន្ធរបស់ខ្ញុំ។*

*ខ្ញុំបានកែសម្រួលពាក្យពេចន៍ខ្លះក្នុងឆ្នាំ១៩៦៨ កាលខ្ញុំទៅ**បំពេញបេសកកម្មនៅ វ៉ឺនសៃ** ក្នុងខេត្តរតនគីរី។*(...)

*ខ្ញុំសូមសម្រក់ទឹកភ្នែកមួយតក់ លើសេចក្តីនឹករលឹកចំពោះមិត្ត មាស-ម៉ានិល។»*

ឡាំងប៉េងសៀក ចូលជាសមាជិកសមាគមអ្នកនិពន្ធខ្មែរ រវាងឆ្នាំ១៩៧០ ហើយនាឆ្នាំ១៩៧២លោកបានចូលទៅក្នុង សមាសភាព គណៈកម្មការបោះពុម្ពផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ[5]។ លោកជាអ្នកចូលចិត្តការតែងនិពន្ធបានផ្តើមតែងនិពន្ធដំបូងនៅឆ្នាំ១៩៦៣ ហើយប្រហែលជាស្លាប់នៅរវាងឆ្នាំ១៩៧៥ ក្នុងសម័យរបបខ្មែរក្រហម។ ស្នាដៃលោកចេញផ្សាយឡើងជាដំបូងចាប់តាំងពីឆ្នាំ១៩៧០ដូចជា៖

- ព្រលឹងម៉ែ, ប្រលោមលោក, ភ្នំពេញ, ១៩៧០,
- ទោសពានរាំង, ប្រលោមលោក, ភ្នំពេញ, ១៩៧១,
- តាពរៀងរះ, ប្រលោមលោក, ភ្នំពេញ, ១៩៧១,
- មេចោរកំបុត ក, ប្រលោមលោក, ភ្នំពេញ, ១៩៧១,
- ខ្លោចចិត្តនៅឡាបានសៀក, ប្រលោមលោក, ភ្នំពេញ, ១៩៧១,
- មហាចោរនៅភ្នំដងរែក[6], ប្រលោមលោក, ភ្នំពេញ, ១៩៧១,

---

[5] សមាសភាពគណៈកម្មការបោះពុម្ពផ្សាយសមាគមអ្នកនិពន្ធខ្មែរ មាន ឡឹកកាំរី ជាប្រធានហើយមាន សមាជិក ៧នាក់៖ **ឡាំងប៉េងសៀក**, គ្រួចប៊ុនលី, តាំងវស្សា, ស៊ូចំរើន, ឈិតវណ្ណច័យ, គង់សម្ភារៈ, យូបូ, ម៉ៅគិមសៀង។ សូមមើល ប្រលោម លោក គង់សុខុម, **ចាស់មុនស្រគាល**, រង្វាន់ក្រមង៉ុយ១៩៧២, ភ្នំពេញ, ១៩៧២ ទំព័រ១៣៩។

[6] អត្ថបទចែងក្នុងទីនេះ ជាវាចារបស់ឡាំងប៉េងសៀក លើក្របប្រលោមលោក

- *ស្រងេះស្រងោច*, ប្រលោមលោក, ភ្នំពេញ, ១៩៧១[7] (ផ្ដើមនិពន្ធនៅឆ្នាំ ១៩៦៣កាលនៅជាសិស្សវិទ្យាល័យស៊ីសុវត្ថិ ក្រុងភ្នំពេញហើយកែសម្រួលចប់នៅរ៉ឺនសៃ ថ្ងៃទី ២០ឧសភា១៩៦៨),
- *ខ្យល់កំបុតត្បូង*, ប្រលោមលោក, ភ្នំពេញ, ១៩៧៣ (និពន្ធនៅរ៉ឺនសៃ ថ្ងៃទី៣០តុលា១៩៦៨ និងកែសម្រួលចប់នៅភ្នំពេញថ្ងៃទី១មេសា១៩៧២)។

---

«**ស្រងេះស្រងោច**» ផ្សាយឲ្យរង់ចាំអាន ប្រលោមដែលនឹងចេញផ្សាយពេលខាងមុខគឺ រឿង«**មហាចោរជៅភ្នំដងរែក**» «ចែងពីប្រវត្តិតស៊ូនៃវរជនខ្មែរមួយក្រុម ដែលលះបង់សេចក្ដីសុខ លះបង់ប្រយោជន៍ផ្ទាល់ខ្លួនធ្វើការបដិវត្តន៍ ដើម្បីឯករាជ្យ សេរីភាព និងវឌ្ឍនភាពរបស់ខ្មែរ។ តែពុទ្ធោ! ផ្លែផ្កានៃការតស៊ូពិតៗត្រូវបានឈ្មោះជាមេចោរទៅវិញ។

«**មហាចោរជៅភ្នំដងរែក**» វែកបញ្ហាខ្មែរនាសម័យព្រេងនាយ សម្ដែងពីដំណើរឫក្សពារ មនោសញ្ចេតនាខ្មែរ ពីឧត្ដមគតិស្នេហាជាតិរបស់បុព្វបុរសខ្មែរ នាំលោកអ្នកអានឱ្យត្រឡប់ចូលទៅក្នុងកាលមួយ ដែលកន្លងផុតទៅហើយ ទុកជាជម្ងឺន្មានដ៏ពិសិដ្ឋសម្រាប់ខ្មែរគ្រប់ឋានៈ គ្រប់វណ្ណៈក្នុងនាបច្ចុប្បន្ននេះ។

«**មហាចោរជៅភ្នំដងរែក**» ជាកម្រងរឿងស្នេហាជាតិ ដែលសម្រាំងជាវណ្ណកម្មឯកប្រចាំជីវិតរបស់អ្នកនិពន្ធ។

«**មហាចោរជៅភ្នំដងរែក**» ធ្វើឱយសកម្មភាពនៃវីរបុរសខ្មែរងើបឡើងវិញ ដែលរំភើបដល់ដួងចិត្តខ្មែរគ្រប់គ្នា។»

[7] ផ្ដើមនិពន្ធរឿងនេះនៅឆ្នាំ ១៩៦៣កាលនៅជាសិស្សវិទ្យាល័យស៊ីសុវត្ថិ ក្រុងភ្នំពេញហើយកែសម្រួលចប់នៅរ៉ឺនសៃ ថ្ងៃទី ២០ឧសភា១៩៦៨។ ដោយលោកជាមន្ត្រីរដ្ឋការ ប្រហែលជានៅឆ្នាំ១៩៦៨ក្រសួងយុត្តិធម៌តម្រូវឲ្យលោក បំពេញ «កាតព្វកិច្ចចាំបាច់ ជាទាហានបំរុង» បានទៅឈរនៅតំបន់រ៉ឺនសៃ។




ខ្យល់កំបុតត្បូង, ក្របក្រៅមុខ



អ្នកនិពន្ធ ឡាំង-ប៉េងសៀក

* កើតក្នុងឆ្នាំ១៩៤៦, ខែកក្កដា ថ្ងៃព្រហស្បតិ៍ទី ២០, នៅកំពង់ធំក្រុង ។ * ឆ្នាំ១៩៥២-៥៣ បានចូលសិក្សាជាដំបូងនៅស្រុកកំណើត *ឆ្នាំ១៩៥៨-៥៩ ជាសិស្សនៅវិទ្យាល័យកំពង់ធំ, រួចវិទ្យាល័យស៊ីសុវត្ថិ បច្ចុប្បន្នវិទ្យាល័យ ៩ តុលា ១៩៧០ ។ * ឆ្នាំ១៩៦៤ ជានិស្សិតនៅមហាវិទ្យាល័យ ហើយចូលបំរើក្នុងក្របខណ្ឌរដ្ឋការ នៅចុងឆ្នាំ ១៩៦៧ ។

* បានបញ្ចេញស្នាដៃអក្សរសាស្ត្រជាដំបូងនៅឆ្នាំ ១៩៦៦ ហើយបោះបង់កិច្ចនិពន្ធនេះនៅឆ្នាំ ១៩៦៨ ដោយសម័យនោះសេរីភាពខាងការសរសេរមានមនុស្សអមនុស្សខ្ទប់ផិតស្លុងទៅ...

* ក្រោយបដិវត្តន៍ ១៨ មីនា ១៩៧០, បានបញ្ចេញស្នាដៃជាច្រើន ទាក់ទងបញ្ហារស់នៅក្នុងសង្គម ដែលក្នុងនោះមានទាំងស្នាដៃស្រាវជ្រាវផ្នែកសេដ្ឋកិច្ចនឹងរបៀបរស់នៅនៃប្រជាជនខ្មែរផង ។

* រឿង ខ្យល់កំបុតត្បូង នេះ ជារណ្ដកម្មដែលសប្រាំងជាពិសេសរបស់អ្នកនិពន្ធ សម្រាប់ដាស់ស្មារតីយុវជន, ប្រជាពលរដ្ឋ ជាកូនជាតិខ្មែរទាំងអស់, សំដែងពីទឹកចិត្តស្នេហាពិតៗរបស់អ្នកនិពន្ធចំពោះមាតុប្រទេស ។

សមាគមអ្នកនិពន្ធខ្មែរ

រោងពុម្ព អប្សរា — តម្លៃ ៣៥៛០០

ខ្យល់កំបុតត្បូង, ក្របក្រៅក្រោយ




ស្រងេះស្រងោច, ក្របក្រៅមុខ




*មេចោរកំបុត ក, គ្របក្រៅមុខ*

*តាមប្រភពអ៊ីនតែណែន [Satya Composer] សន្និដ្ឋានថា លោកឡាំងប៉េងសៀក តែងនិពន្ធ ប្រលោមលោកខ្លះៗទៀតដោយឲ្យនាមប៉ាកាថា«កាណែល»៖*

*«លោកឡាំង ប៉េងសៀក ជាអ្នកនិពន្ធដ៏មានកេរ្តិ៍ឈ្មោះបោះសំឡេងម្នាក់ ក្នុងទសវត្សរ៍ឆ្នាំ៧០ ហើយមានប៉ាកកានាមថា កាណែល ។ លោកកើតនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៤៦ នៅភូមិកំពង់ថ្ម ស្រុកកំពង់ថ្ម ខេត្តកំពង់ធំ ។ កាលនៅក្មេង លោកបានចូល*

រៀននៅវិទ្យាល័យទីរួមខេត្តកំណើតរបស់លោក ក្រោយមកផ្លាស់មករៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ។ ឆ្នាំ១៩៦៤ លោកបានចូលសិក្សានៅមហាវិទ្យាល័យច្បាប់ ។ ហើយពីរឆ្នាំក្រោយមក លោកបានទទួលសញ្ញាប័ត្រច្បាប់ លុះឆ្នាំ១៩៦៧ លោកបានជាប់សញ្ញាប័ត្រក្រឡាបញ្ជីក្នុងតុលាការ ។ លោកជាមនុស្សដែលតែងតែប្រឆាំងនឹងរបៀបកាត់ទោសរបស់ពួករាជានិយម និងសាធារណរដ្ឋនិយម ដែលគេអាចមើលឃើញទំនោររបស់លោកប្រឆាំងនឹងពួកអ្នកមាន និងអ្នកធំដែលរកទ្រព្យសម្បត្តិ ឬ បុណ្យស័ក្តិ ដោយការជិះជាន់គេ ហើយប្រើទ្រព្យសម្បត្តិ ឬ បុណ្យស័ក្តិនោះដើម្បីជិះជាន់គេថែមទៀត ដូចជានៅក្នុងរឿង កូនអើយឥតម៉ែ ជាដើម។ ស្នាដៃរបស់លោក មានក្នុងឈ្មោះ ឡាំង ប៉េងសៀក មួយពួក និង ឈ្មោះ កាណែល មួយពួក។

-ស្នាំដៃក្នុងឈ្មោះ ឡាំង ប៉េងសៀកៈ

១. រឿង ព្រលឹងម៉ែ , ឆ្នាំ១៩៧០

២. រឿងខ្មោចចិត្តនៅឡាបានសៀក , ឆ្នាំ១៩៧១

៣. រឿង ទោសពានរាំង , ឆ្នាំ១៩៧១

៤. មហាចោរភ្នំដងរែក , ឆ្នាំ១៩៧១

៥. មេចោរកំបុត ក , ឆ្នាំ១៩៧១

៦. កំហែងរាជ , ឆ្នាំ១៩៧២

៧. ជំងឺសករាជ , ឆ្នាំ១៩៧២

៨. ស្រងេះស្រងោច , ឆ្នាំ១៩៧២

៩. សេនាកំហែង , ឆ្នាំ១៩៧២
១០. តាពរៀងរះ , ឆ្នាំ១៩៧២
១១. ខ្យល់កំបុតត្បូង , ឆ្នាំ១៩៧៣
១២. ឆ្ងាយដាច់អាល័យ , ឆ្នាំ១៩៧៣

- ស្នាដៃក្នុងឈ្មោះ កាណែល
១. រឿង វីយូឡុងស្នេហា , ឆ្នាំ១៩៧២[8]
២. រឿង ចិត្តស្មោះ , ឆ្នាំ១៩៧៣
៣. រឿង ជ្រោះអូរយ៉ាដាវ , ឆ្នាំ១៩៧៣
៤. រឿង ទំនួញក្មេងកំព្រា , ឆ្នាំ១៩៧៣
៥. រឿង ស្ទឹងសម្ងាត់ , ឆ្នាំ១៩៧៣
៦. រឿង កូនអើយឥតម៉ែ , ឆ្នាំ១៩៧៥
៧. រឿង ស្នេហ៍ដូចជាមិនស្នេហ៍ , ឆ្នាំ១៩៧៥»

---

[8] នៅបណ្ណាល័យសកលវិទ្យាល័យខ័រណែល ក្នុងបញ្ជីសៀវភៅខ្មែរ បញ្ជាក់ ថា ឡាំងប៉េងសៀក (Know as Kānel) ស្គាល់ក្នុងនាម កាណែល ចំពោះរឿងវីយូឡុងស្នេហា នេះ ក្នុង « Khmer vernacula-catalog » of Cornell University Libraries. សៀវភៅនេះចុះលេខបញ្ជី C-344




សេចក្តីសង្កេត៖

យើងមិនទាន់អាចសន្និដ្ឋានជាដាច់ណាត់ថា នាមអ្នកនិពន្ធ **កាណែល** ជា នាមប៉ាកកា លោក**ឡាំងប៉េងសៀក**នៅឡើយទេ គឺ យើងត្រូវការ ធ្វើការស្រាវជ្រាវបន្ថែមដើម្បីឲ្យមានពន្លឺជាងនេះទៅទៀត។ តែយើងសង្កេតឃើញ ក្នុង ប្រលោមលោក «ស្រដេះសង្រោច» របស់ឡាំងប៉េងសៀក មានរាយតួអង្គឈ្មោះ **កាណែល**

ជាមិត្តនាម **មាស-ម៉ានិល** ចាប់ពីទំព័រ១០១ ទៅ។ តាមរបៀបសរសេរ បុរសឈ្មោះ **កាណែល** នេះគឺ តំណាងអ្នកនិពន្ធផ្ទាល់ ។ល។ ហេតុនេះត្រូវការអានប្រលោមលោក របស់ឡាំងប៉េងសៀក មួយចំនួនទៀតដើម្បីឲ្យដឹងពិតពីឈ្មោះ**កាណែល**នេះជានាមប៉ាកការបស់**ឡាំងប៉េងសៀក**ឬយ៉ាងណា។ល។ ជាបណ្តោះអាសន្ន យើងអាចសន្និដ្ឋានបានថា លោក**ឡាំងប៉េងសៀក**និងលោក**កាណែល**មានទំនាក់ទំនងនឹងគ្នាយ៉ាងស្អិតរមួតហាក់ដូចបុគ្គលតែម្នាក់ប៉ុណ្ណោះ។ តែជីវប្រវត្តិ **ឡាំងប៉េងសៀក** ខាងនេះនៅក្នុងការស្រាវជ្រាវបន្តទៅទៀត មិនមែនជាទីបញ្ចប់ទេ។ នេះគួរសិក្ខាកាមជន ជំនាន់ក្រោយបន្តការស្រាវជ្រាវបែបនេះបន្តទៅទៀត ព្រោះមនុស្សចាស់ជំនាន់មុនភ្នែកគាត់ក៏អន់ កម្លាំងគាត់ក៏ខ្សោយ តែការសិក្សា អក្សរសាស្ត្រជាដង្ហើម វប្បធម៌ អរិយធម៌ខ្មែរ និង ជាជន្ទល់អត្តសញ្ញាណជាតិយើង ព្រោះ សាកលភាវូបនិយកម្ម មានសង្វាក់លឿនជាអនេក ចំពោះប្រជាជនខ្មែរ រស់នៅក្នុងប្រទេសតូចតាច។ល។

ពេលថ្មីៗបានរកឃើញសៀវភៅពីរក្នុងបណ្ណាល័យនិពន្ធដោយ **កាណែល**៖

១- ទំនួញក្មេងកំព្រា, ភ្នំពេញ, ការផ្សាយរបស់ទីចាត់ការសារព័ត៌មាន អរិយធម៌, ១៩៧៣, ២ភាគ។




ទំនួញក្មេងកំព្រា ក្របក្រៅ

២- សត្វរំពេ, ភ្នំពេញ,១៩៧៥, ៥១ ទំព័រ។




សត្វរំពេក្របក្រៅ



# បុប្ផាស៊ីវិលសង្វេ

**FLEUR DE REVE**

... ជាបុប្ផាក្នុងសុបិន... ជាបុប្ផាដ៏ក្រអូប, ជាសត្វរំពៃដែលហិចហើរឆ្លងមហាសមុទ្ទ ទោះឆ្ងាយដាច់សង្វែងយ៉ាងណាក៏មិនបោះបង់ចោលសមុទ្ទដែរ ។

... គឺកម្រងរឿងស្នេហាដ៏ល្អ សម្រាប់យុវជន . យុវតី, មានសំនួនវោហារប្លែក, ជាប្រទីបផ្កាលាសម្រាប់ស្វាមី-ភរិយា ឬគូស្រករដែលទើបជួបគ្នាថ្មី ៗ ។

អ្នកនិពន្ធ ការ៉ៃណាល ខិតខំសរសេររឿងនេះតាំងពីខែកក្កដា ១៩៧៣, សម្រាំងជាស្នាដៃឯក *ចេញផ្សាយជាពិសេសសម្រាប់ថ្ងៃ ២០ កក្កដា ១៩៧៥ ដែលជាថ្ងៃខួបកំណើត...។*

*សូមកុំភ្លេច* បុប្ផាស៊ីវិលសង្វេ

*តែងដោយ* ការ៉ៃណាល

តម្លៃ រៀល

*សត្វរំពេ គ្របក្រៅខាងក្រោយ*

*នៅទំព័រដើមមុនកំណត់អ្នកនិពន្ធ រឿងសត្វរំពេ របស់* **ការ៉ៃណាល** *នេះ មានកំណាព្យមួយជាភាសាបារាំងតែងដោយ ឡាំងប៉េងសៀកផ្ទាល់ដោយមានចែងឈ្មោះលោកដូចមានសម្រង់ទាំងស្រុងភ្ជាប់ទីនេះ៖*

« *សូមជូនកំណាព្យ* CHANT DE SANG *ដល់ប្អូនៗយុវជនសិស្សានុសិស្ស និស្សិតចូលចិត្តអានស្នាដៃខ្ញុំ ជាពិសេសចំពោះអ្នកអានដែលស្នើខ្ញុំអោយបញ្ចេញស្នាដៃអោយបានច្រើន។*

CHANT DE SANG

Petit serin qui veut chanter
Quel air veux-tu que je t’écrive
La plume que tu m’as donnée
Flotte indécise à la dérive.
L’heure est-elle aux hymnes de joie
Entends les pleurs d’âmes en peine
Le temps est-il aux chants d’amour
N’entends-tu pas les cris de haine.

Entends tonner gronder la guerre
Comment peux-tu chanter la paix
Vois-tu la mort meurtrir la terre
Peux-tu jamais chanter la vie

N’insiste pas pour [que][9] je t’écrive
Petit serin ivre de chant
Sais-tu qu’il faudrait que tu crèves
Ta plume écrit avec ton sang…

Païlin, le 2 mars 1975

LAING PENGSIEK. »

*កំណាព្យនេះជាស្នាដៃចុងក្រោយរបស់* ឡាំងប៉េងសៀក *ដែលបានផ្សាយនៅថ្ងៃ២មិនា១៩៧៥ មុនពេលខ្មែរក្រហមចូលមកកាន់កាប់កម្ពុជា នាថ្ងៃ៧មេសាឆ្នាំ១៩៧៥។*

---

[9] *ពាក្យ* « QUE » *នេះខ្ញុំថែមដើម្បីឱ្យត្រូវតាមវេយ្យករណ៍បារាំង។*

*ប្រលោមលោក អ្នកនិពន្ធកាណែល បានផ្សាយពាណិជ្ជកម្ម ដោយបែងនៅទំព័រក្រោយប្រលោមលោក សត្វរំពេ (បោះពុម្ពនៅថ្ងៃ៥មិនា១៩៧៥) ថា « ស្នាដៃអ្នកនិពន្ធដដែល ដែលនឹងចេញផ្សាយជាបន្តបន្ទាប់៖*

*១- រឿង « ជីវិតនាងខ្ញុំ » (កំពុងបោះពុម្ព)*

*២-រឿង « បុប្ផាស្នឹងសង្កែ »*

*៣-រឿង « លាហើយ »… »*

*តែប្រលោមលោកចុងក្រោយទាំង៣នេះពុំឃើញមានចេញផ្សាយទេ ព្រោះកម្ពុជាធ្លាក់ ក្នុងកណ្តាប់ដៃ រដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យ ក្រោមការដឹកនាំខ្មែរក្រហម។*

*សរសេរចប់នៅ ភូមិ កូលេស្មៀងថ្ងៃទី៣១មិនា២០១៥*

*ប្រមូលឯកសារចងក្រងដោយ*

*បណ្ឌិតសភាចារ្យ* **ឃីង ហុកឌី**